- Reçue le 4-10-51 -

INDOCHINE FRANÇAISE RÉGIE DU DÉPÔT LÉGAL

# មិត្តសាលាបាលី

ទស្សនាវដ្ដីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ

ចេញរាល់ខែ



ឆ្នាំទី ២ – ខែមីនា លេខ ៣

ព.ស. ២៤៩៤ - គ.ស. ១៩៥១

ទស្សនាវដ្ដីអនុមាសផ្សាយព្រះពុទ្ធសាសនានិងអក្សរសាស្ត្រខ្មែរ

បណ្ណាធិការ ឈឹម - ក្រសេម

សំណាក់ការ លេខ ៣៨ អា., វិថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ

## បញ្ជីរឿង

| | | ទំព័រ |
|---|---|---|
| វិចារណកថា | | ៨១ |
| អគ្គញ្ញសូត្រ (សេចក្ដីបំប្រួញ) | ញូង · សៀង | ៩៤ |
| ព្រះភវប្រវត្តិសម្ដេចព្រះមហាសង្ឃ ធី ទៀង | | ៩៣ |
| ការសាងអាយតនៈ (តទៅពីលេខមុន) | តែ - ជុំ | ១០២ |
| បញ្ចគន្ធៈ (តមក) សេចក្ដីប្រែរបស់ | ភិក្ខុយ៉ាំង · ខាត់ | ១១៤ |

---

ដំឡៃជាវប្រចាំឆ្នាំ ១០០ រៀល

---

អ្នកអានទាំងឡាយ! សូមអញ្ជើញចុះឈ្មោះជាវ!

នឹងបបួលញាតិមិត្តជួយជាវ!

ជីវិតទស្សនាវដ្ដីសូមផ្ញើលើលោកអ្នក ៗ

សាធារណរដ្ឋប្រជាមានិតកម្ពុជា
បណ្ណាល័យជាតិ
លេខកូដ : ........


# វិជារណាគាថា

ការបរិភោគអាហារ, ការដេក, ភ័យនឹងសេពកាម ធម៌ទាំង ៤ ប្រការនេះ មនុស្សនឹងសត្វតិរច្ឆានមានដូចគ្នា មិនប្លែកពីគ្នាទេ ៗ ធម៌ឯទៀតៗ ត្រូវមានសាលារៀន មានគ្រូអាចារ្យបង្ហាត់បង្រៀន ទើបចេះដឹងបាន, ឯធម៌ ៤ ប្រការខាងលើនេះ មិនចាំបាច់ទេ, ចេះដឹងឯងៗ ដូចគ្នាទាំងមនុស្សទាំងសត្វតិរច្ឆាន ៗ

ការកើតមកជាមនុស្សហើយគ្រាន់តែស៊ីដេក ភ័យនឹងសេពកាមតែប៉ុណ្ណោះ ឈ្មោះថាធ្វើបុកជោក ៗ តាមសភាពធម្មតា មនុស្សនឹងតិរច្ឆានតែងប្រកបដោយធម៌ ៤ ប្រការនេះ ទើបលោកហៅថា "សត្វ" ទាំងអស់ ៗ មានតែធម៌គឺវិជ្ជាលោក វិជ្ជាធម៌នេះទេ ដែលអាចធ្វើមនុស្សនឹងតិរច្ឆានឲ្យវិសេសប្លែកពីគ្នាបាន ក្រៅពីធម៌គតមានអំណាចអ្វីជួយឲ្យវិសេសប្លែកបានឡើយ ៗ មនុស្សមានធម្មសញ្ញាប្រសើរជាងសត្វ តែបើមិនបានទទួលការសិក្សាធម៌គឺវិជ្ជាលោក វិជ្ជាធម៌ហើយ ក៏ឋិតនៅតាមសភាពដើមជាអរញ្ញធម៌ (Sauvage) លុះបានទទួលការសិក្សាធម៌ទាំងនោះហើយតែមិនប្រតិបត្តិតាម នៅធ្វើបុកជោក មារយាទអាក្រក់ មិនមានសីលធម៌ នុ៎ះក៏នៅតាមសភាពជាអរញ្ញធម៌ដដែល ៗ អ្នកដែលបានសិក្សាធម៌ហើយ តាំងចិត្តប្រតិបត្តិតាម ខំប្រឹងផ្លាស់គំនិតចិត្តថ្មី ផ្លាស់និស្ស័យអាក្រក់ បុកគោថោកទាបចោលចេញ ទើបអាចផ្លាស់

សភាពជាអរញ្ញធម៌ទៅកាន់សភាពខ្ពង់ខ្ពស់ជាគាមធម៌ (civilisation) បាន ព្រោះវិជ្ជានាំឲ្យមានវិន័យ, វិន័យនាំឲ្យមានសេចក្ដីថ្លៃថ្នូរ, សេចក្ដីថ្លៃថ្នូរ នាំឲ្យបានទ្រព្យ, ទ្រព្យនាំឲ្យបានសុខ ៗ ដូច្នេះ ឃើញថា វិជ្ជាអាច ផ្លាស់និស្ស័យថោកទាប នាំឲ្យមាននិស្ស័យខ្ពង់ខ្ពស់បាន, បានជាលោក ពោលថា "មានតែព្រះធម៌គឺវិជ្ជាលោក វិជ្ជាធម៌" នេះទេ ទើបអាច ធ្វើមនុស្សនឹងតិរច្ឆានឲ្យវិសេសប្លែកពីគ្នា ៗ ឯការយល់ឃើញថា បុគ្គល មិនអាចផ្លាស់និស្ស័យថោកទាប មារយាទអាក្រក់បាននោះ គឺជា សេចក្ដីយល់បែបអរញ្ញធម៌ទេ, ទស្សនៈនេះមិនត្រូវតាមគន្លងធម៌ទេ ឥត មានដើមគម្ពីរអាងបានឡើយ ៗ មនុស្សដែលមិនបានទទួលការសិក្សា ឬ ដែលបានទទួលហើយ តែមិនព្រមផ្លាស់និស្ស័យថោកថយ មារយាទ អាក្រក់ពាលចេញ នៅបណ្ដោយតាមសភាពដើមជាអរញ្ញធម៌ លោក ហៅថាមនុស្សតិរច្ឆាន តាមដំណើរដែលមានដូចសត្វតិរច្ឆាន ៗ មនុស្ស ណាបានទទួលការសិក្សាហើយ ប្រតិបត្តិតាម យកវិជ្ជាលោក វិជ្ជា ធម៌ជាបទដ្ឋាន ធ្វើអ្វីធ្វើតាមធម៌ តាមច្បាប់ អាចកើតបានទៅជាមនុស្ស មានឫកពាខ្ពង់ខ្ពស់ មារយាទថ្លៃថ្នូរ អាចារៈល្អ មានសីលធម៌ មានចិត្ត ប្រកបដោយមេត្តាករុណាចំពោះសត្វលោក, លោកហៅមនុស្សនោះថា មនុស្សទេព ៗ នៅក្នុងលោកនេះ អ្នកមានវិចារណញ្ញាណអាចសង្កេត ឃើញប្រច័ក្សនូវបុគ្គលិកលក្ខណៈនៃមនុស្សទូទៅ បានជាអ្នកប្រាជ្ញទូន្មាន ប្រៀនប្រដៅឲ្យវៀរបង់នូវធម៌អាក្រក់ ឲ្យសេពគប់ធម៌ល្អ ៗ

ព្រះពុទ្ធជាម្ចាស់ជាកំពូលអ្នកប្រាជ្ញ ទ្រង់ព្រះនាមអនុត្តរោ ព្រោះព្រះអង្គប្រកបដោយអាចារៈថ្លៃថ្នូរ ឫកពាខ្ពង់ខ្ពស់ មានសីលធម៌ប្រសើរដ៏លើសលុប មានព្រះទ័យបរិសុទ្ធ កន្លងផុតសត្វលោក ៗ ទ្រង់ប្រសើរផុតបែបនេះ នឹងថាព្រោះតែព្រះអង្គជាទេវតា ឬព្រះព្រហ្មក៏មិនមែន ជាព្រះឥន្ទ្រាធិរាជក៏ពុំមែនដែរ គឺទ្រង់ជាមនុស្សដូចយើង តែព្រះអង្គប្រកបដោយវិជ្ជា ទ្រង់ផ្លាស់និស្ស័យអាក្រក់ចោល យកព្រះធម៌ជានិស្ស័យព្រះអង្គវិញ ទាល់តែមនុស្សទេវតាមារព្រហ្មយមយក្ស ទទួលស្គាល់ព្រះអង្គ ហើយគោរពបូជាព្រះអង្គដោយគ្រឿងសក្ការៈដ៏ក្រៃលែង ៗ កាលបានត្រាស់ដឹងហើយ ស្ដេចទ្រង់ប្រកាសពុទ្ធសាសនាទូន្មានវេនេយ្យសត្វ ឲ្យបានល្អដូចព្រះអង្គផង កុំឲ្យនៅថោកទាបតទៅទៀត គឺទ្រង់ទូន្មានឲ្យខំស្វែងរកវិជ្ជា រកទ្រព្យ រក្សាទ្រព្យ សេពគប់កល្យាណមិត្ត ចាយវាយឲ្យសមតាមកំឡាំងទ្រព្យ ឲ្យរក្សាសីល ធ្វើចិត្តឲ្យប្រកបដោយមេត្តាករុណារាប់អានស្រឡាញ់គ្នា, រួមសេចក្ដីមកក៏គឺញ៉ាំងសង្គមមនុស្សឲ្យមានសីលធម៌ល្អ កុំឲ្យថោកទាប ឲ្យពិសេសប្លែកពីសត្វតិរច្ឆានសមដូចព្រះតម្រាស់ថា "ហីនំ ធម្មំ ន សេវេយ្យ=កុំសេពគប់ធម៌ថោក" បានសេចក្ដីថាកុំធ្វើឫកថោកឲ្យសោះ ៗ បើមនុស្សទាំងអស់បានប្រតិបត្តិតាមពុទ្ធោវាទឥតឃ្លៀងឃ្លាតហើយ មនុស្សលោកនេះ នឹងប្រែក្លាយទៅជាទេវលោកដោយពិត ៗ

ម្នាលអានន្ទ! អ្នកណាមួយ ទោះជាភិក្ខុក្តី ជាភិក្ខុនីក្តី ជាឧបាសកក្តី ជាឧបាសិកាក្តី ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌, អ្នកនោះទើបឈ្មោះថាធ្វើសក្ការៈ គោរព រាប់អាន និងបូជា ចំពោះតថាគត ដោយការបូជាដ៏ប្រសើរបំផុត ។

មហាបរិនិព្វានសូត្រ មហា. ទីឃ.

# អគ្គញ្ញសូត្រ

## ទីឃនិកាយបាដិកវគ្គ

(សេចក្តីបំប្រួញ)

ដំណាលតាមសេចក្តីប្រារព្ធខាងដើមថា: សម័យមួយព្រះដ៏មានបុណ្យទ្រង់គង់នៅក្នុងមិគារមាតុប្រាសាទ (ប្រាសាទនាងវិសាខា) ក្នុងវត្តបុព្វារាមជិតក្រុងសាវត្ថី ។ មានសាមណេរ ២ រូប ឈ្មោះវាសេដ្ឋៈ និងភារទ្វាជៈ ជាត្រកូលព្រាហ្មណមហាសាល បានចូលទៅគាល់ព្រះអង្គដែលទ្រង់ចេញចាកទីសម្ងំ ហើយចុះទៅចង្ក្រមត្រង់ម្លប់ប្រាសាទនោះ ៗ ព្រះសម្ពុទ្ធទ្រង់ត្រាស់សួរថា អ្នកទាំងឡាយជាជាតិព្រាហ្មណ៍ ជាត្រកូលព្រាហ្មណ៍ ហើយបានចូលមកបួសក្នុងពុទ្ធសាសនាដូច្នេះ ពួកព្រាហ្មណ៍គេមិនជេរប្រទេចបន្តុះបង្អាប់ទេឬ? វាសេដ្ឋសាមណេរ ក៏ក្រាប

ទូលថា: "សូមទ្រង់ព្រះមេត្តាប្រោស ពួកព្រាហ្មណ៍បានជេរប្រទេច
យើងខ្ញុំព្រះអង្គពេញទីដោយឥតសំចៃមាត់ទេ ហើយគេលើកតំកើងតែពួក
ព្រាហ្មណ៍យ៉ាងនេះថា មានតែពួកព្រាហ្មណ៍ទេ ទើបជាវណ្ណៈប្រសើរ
បំផុត ជាវណ្ណៈសបរិសុទ្ធ, ពួកជនឯទៀតដែលមិនមែនជាព្រាហ្មណ៍
សុទ្ធតែជាវណ្ណៈថយថោក ជាវណ្ណៈខ្មៅមិនបរិសុទ្ធទាំងអស់, ពួក
ព្រាហ្មណ៍ ជាឱរសរបស់ព្រហ្មកើតអំពីព្រះឱស្ឋព្រហ្ម ព្រហ្មបុ:នគាក់
តែងបង្កើតមក ជាទាយាទ (ញាតិអ្នកទទួលកេរ្តិ៍សំបាច់) របស់ព្រហ្ម,
ឯអ្នកទាំងឡាយ ពុំគួរបើប្រុយលះបង់ចោលវណ្ណៈដ៏ប្រសើររបស់ខ្លួន
ចោល ហើយត្រឡប់មកចូលដៃគ្នានឹងពួកសមណៈត្រងោល ដែលជា
គហបតីវណ្ណៈខ្មៅថោកថយ ជាពួកនៃមារ កើតអំពីព្រះបាទព្រហ្មដូច្នេះ
វិញសោះ" ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា "អើវាសេដ្ឋៈនឹង
ភារទ្វាជៈ ពួកព្រាហ្មណ៍មិនបានដឹងនូវការកកើតឡើងនៃលោកជាដំបូង
ទេ ទើបបាននិយាយយ៉ាងនេះ, ពួកព្រាហ្មណ៍សឹងធ្លាប់បានឃើញ
ប្រាកដស្រាប់ហើយតើ ដូចជាពួកនាងព្រាហ្មណី ដែលមានរដូវក្តី
មានគភ៌ក្តី កំពុងសម្រាលកូនក្តី បំបៅកូនក្តី គឺព្រាហ្មណ៍ទាំងនោះ
ឯង សុទ្ធតែកើតមកអំពីយោនីនាងព្រាហ្មណីជាមាតារៀងៗខ្លួនទាំងអស់;
កាលបើដូច្នេះ, ការពោលពាក្យតំកើងខ្លួនឯងនោះឈ្មោះថាជាពាក្យបង្អាប់
ព្រាហ្មណ៍ផង ជាពាក្យកុហកផង ហើយជាហេតុនាំឲ្យបានបាបច្រើន ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់តទៅទៀតថា វណ្ណៈទាំងអស់មាន ៤ គឺ ខត្តិយៈ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ ។ ក៏បណ្ដាវណ្ណៈទាំង ៤ នេះ វណ្ណមួយៗ រមែងមានអាក្រក់មានល្អ, មិនមែនសុទ្ធតែអាក្រក់ មិនមែនសុទ្ធតែល្អទេ គឺថាកងក្រុមវណ្ណៈមួយៗនោះ អ្នកខ្លះក៏ប្រព្រឹត្តធ្វើអកុសលកម្មបថទាំង ១០ ប្រការពេញបន្ទុក, អ្នកខ្លះក៏បានប្រព្រឹត្តតែកុសលកម្មបថតែម្យ៉ាង កាលបើវណ្ណៈទាំង ៤ នេះឯង ប្រព្រឹត្តប្រឡូកប្រឡំគ្នាក្នុងធម៌ខ្មៅនិងសទាំងពីរដូច្នេះទេ ម្ដេចក៏ពួកព្រាហ្មណ៍ហ៊ាននិយាយអួតអាងសរសើរវណ្ណៈខ្លួនតែម្យ៉ាងដូច្នេះ ។ វិញ្ញូជនទាំងឡាយមិនយល់ព្រមតាម គឺមិនសរសើរនូវពាក្យរបស់ព្រាហ្មណ៍ទាំងនោះទេ ព្រោះជាការមិនពិត, លុះណាតែបណ្ដាវណ្ណៈទាំង ៤ ពួកនេះវណ្ណៈឯណាមួយ ជាភិក្ខុឆ្ងាយចាកកិលេសអស់អាសវៈ បានប្រព្រឹត្តព្រហ្មចរិយធម៌រួចហើយ បានធ្វើសោឡសកិច្ចរួចហើយ មានចិត្តផុតស្រឡះហើយចាកកិលេស ព្រោះបានត្រាស់ដឹងដោយប្រពៃ. វណ្ណៈនោះទើបបានឈ្មោះថាជាបុគ្គលប្រសើរលើសជាងវណ្ណៈទាំងឡាយ, រូបរួមសេចក្ដីមកថា វណ្ណៈណាក៏ដោយ ដែលនឹងត្រូវទទួលឈ្មោះថាជាអ្នកបរិសុទ្ធវិសេសផុតគេនោះ, លុះត្រាតែខ្លួនបានប្រព្រឹត្តធម៌ពេញលេញបានយកធម៌ជាគោល ព្រោះថាធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជនទាំងបច្ចុប្បន្ននិងបរលោក ។

ព្រះអង្គទ្រង់បញ្ជាក់ចំពោះ សាមណេរទាំងពីររូបថា: "អ្នកទាំងឡាយដែលមានជាតិផ្សេងៗគ្នា មានឈ្មោះនឹងគោត្រត្រកូលផ្សេងៗគ្នា ហើយបានលះចោលផ្ទះសម្បែងមកកាន់ផ្នួស, បើមានគេសួរថា លោកទាំងឡាយជាអ្វី នោះចូរប្រាប់ទៅគេវិញថា យើងជាសមណសក្យបុត្រ ។ បើជនណាមានការជឿស៊ប់ចំពោះតថាគតហើយ ទោះបីអ្នកណាមួយជាសមណព្រាហ្មណ៍ក្តី ទេវតា មារ ព្រហ្មក្តី ក៏ពុំអាចនឹងបង្វិលជននោះឲ្យបែរត្រឡប់ទៅផ្សេងវិញបានឡើយ ជននោះ គួរនិយាយយ៉ាងនេះថា ខ្ញុំជាឱរសនៃព្រះដ៏មានបុណ្យ កើតមកអំពីព្រះឱស្ឋរបស់ព្រះដ៏មានបុណ្យ កើតមកអំពីធម៌ ធម៌បានតាក់តែងមក ជាទាយាទរបស់ធម៌" ។ ព្រោះហេតុអ្វី បានជាព្រះអង្គទ្រង់ត្រាស់ដូច្នេះ! ព្រោះពាក្យថា "ធម្មកាយ" ក្តី "ព្រហ្មកាយ" ក្តី "ធម្មភូត" ក្តី "ព្រហ្មភូត" ក្តី គឺជាឈ្មោះរបស់ព្រះដ៏មានជោគជ័យប៉ុណ្ណោះ ។

ដើម្បីបដិសេធនូវអំនួតរបស់ពួកព្រាហ្មណ៍, ព្រះសម្ពុទ្ធទ្រង់សំដែងតំណាលអំពីការកកើតលោកជាដំបូងចំពោះសាមណេរទាំងពីររូប ដូចសេចក្តីតទៅនេះ :–

គង់សម័យដែលលោកនេះត្រូវវិនាសម្តងៗដោយអំណើះទៅនៃកាលដ៏យូរអង្វែង, មានពួកសត្វបានទៅកើតក្នុងអាភស្សរព្រហ្មជាច្រើន, ពួកសត្វទាំងនោះ កើតបានដោយឈានចិត្ត ជាឧបបាតិកកំណើត មាន

បីតិជាអាហារ មានរស្មីភ្លឺចេញពីខ្លួន ត្រាច់ទៅតាមអាកាសបាន ស្ថិតនៅក្នុងវិមានដ៏ល្អអស់កាលជាយូរលង់ ៗ លុះដល់កាលកន្លងជាយូរអង្វែងទៅ លោកនេះក៏ត្រូវចំរើនឡើងវិញ; ក្នុងសម័យនោះ សត្វទាំងឡាយនោះច្យុតចាកអាភស្សរព្រហ្មមកកើតនៅមនុស្សលោកនេះ ដោយឈានចិត្តនឹងមានបីតិជាអាហារដូចគ្នា ៗ សម័យនោះឯងចក្រវាឡទាំងអស់ក៏រលាយទៅជាទឹកចូលគ្នា មានតែងងឹតសូន្យសុង គ្មានព្រះចន្ទនឹងព្រះអាទិត្យ, គ្មានផ្កាយ, គ្មានយប់នឹងថ្ងៃ គ្មានកំណត់កាលមួយខែនឹងកន្លះខែ គ្មានរដូវនឹងឆ្នាំ ទាំងភេទស្រីនឹងប្រុសក៏មិនប្រាកដ ៗ សត្វទាំងឡាយក៏គ្រាន់តែរាប់ថាជាសត្វៗប៉ុណ្ណោះ ៗ លុះកាលកន្លងពីនេះយូរអង្វែងទៅទៀត ផែនដីមានឱជារសក៏កើតប្រាកដឡើងអណ្តែតត្រាដាសពាសលើទឹក សម្រាប់សត្វទាំងនោះ, ជារបស់មានក្លិនក្រអូបមានរសផ្អែម មានសម្បុរល្អដូចទឹកដោះថ្លា ឬទឹកដោះខាប់ មានរសឆ្ងាញ់ពិសាដូចជាទឹកឃ្មុំដែលលាយដោយកូនឃ្មុំ ដូច្នោះឯង ៗ គ្រានោះមានសត្វមួយជាអ្នកប្រុលរបួចគិតថា យីអើ នេះជាអ្វីអេះ ក៏យកចុងដៃទៅឆ្កឹះយកផែនដីអណ្តែតលើទឹកនោះ មកលិទ្ធភ្លក្សមើល ស្រាប់តែមានឱជារសឆ្ងាញ់ពិសាជ្រួតជ្រាបទៅគ្រប់សព្វសរសៃទាំងអស់ ដែលសម្រាប់ទទួលរសជាតិ ទើបកើតមានចំណង់ស្រេកឃ្លានចង់តែភ្លក្សមើលតទៅទៀត ៗ ពួកសត្វដទៃទៀតបានឃើញដូច្នោះ ក៏តាំងយក

តម្រាប់សត្វនោះតៗគ្នា ដោយយកចង្អុលដៃទៅលូកឆ្កេះយកផែនដីនោះ មកលិទ្ធភ្លក្សមើលហើយក៏ញ៉ាមទាំងអស់គ្នា ៗ បន្ទាប់ពីលូកលិទ្ធនេះ ទៅក៏តាំងនាំគ្នាគកាយខ្វេះយកផែនដីនោះមកធ្វើជាពំនូតបរិភោគឃ្មុម ៗ តែ ម្តង ៗ គង់ពេលដែលសត្វទាំងឡាយពូតដីបរិភោគដូច្នោះ ពន្លឺដែលភ្លឺ ចេញឯងពីខ្លួនក៏សាបសូន្យបាត់ទៅ ៗ លុះពន្លឺនោះវិនាសបាត់ទៅហើយ ទើបកើតមានព្រះចន្ទនឹងព្រះអាទិត្យឡើង ៗ មានព្រះចន្ទនឹងព្រះអាទិត្យ ហើយ ក៏តាំងកើតមានផ្កាយទាំងឡាយឡើងទៀត ៗ បន្ទាប់ពីនោះមក, ទើបកើតមានយប់នឹងថ្ងៃ, ខែ, រដូវនឹងឆ្នាំជាលំដាប់តៗគ្នាឡើង ៗ លោក នេះចំរើនឡើងវិញដោយហេតុប៉ុណ្ណោះឯង ៗ

កាលដែលពួកសត្វទាំងឡាយនោះ បរិភោគតែផែនដីមានឱជារស ដូច្នោះអស់កាលដ៏អង្វែងយូរ ៗ ទៅ សេចក្តីរឹងប៉ឹងក្នុងរាងកាយក៏កើត ប្រាកដឡើង ទាំងពណ៌សម្បុរក៏ប្រែប្រួលៗគ្នាឡើងដែរ គឺសត្វខ្លះមាន សម្បុរល្អ សត្វខ្លះមានសម្បុរអាក្រក់ ៗ ពួកសត្វដែលមានសម្បុរល្អ តាំងមើលងាយពួកសត្វមានសម្បុរអាក្រក់ ៗ ពីព្រោះតែមានសេចក្តី ប្រកាន់ខ្លួននឹងការមើលងាយសម្បុរគ្នាដូច្នោះ, ផែនដីដ៏មានឱជារសក៏ សាបសូន្យបាត់ទៅ ៗ កាលបើដូច្នេះ ពួកសត្វទាំងនោះក៏មកប្រជុំគ្នា ហើយត្អូញត្អែរស្តាយស្រណោះផែនដីមានរសឆ្ងាញ់នោះក្រៃពេក ៗ គ្រា នោះ សត្វទាំងឡាយនោះនាំគ្នានឹករកអក្ខរៈដែលជាច្បាប់បុរាណ (គឺសំដី

ជារឿងដែលកើតឡើងសម្រាប់លោក), ប៉ុន្តែមិនអាចនឹងយល់សេចក្តីនៃអក្ខរៈនោះបានឡើយ ។

លុះផែនដីមានផ្ទុជារស វិនាសអស់ទៅ, ក្រមរដីក៏កើតឡើងទៀត ។ ក្រមរដីនោះមានទំនងដូចជាផ្សិតក្បាលពស់ ជារបស់មានសម្បុរល្អមានក្លិនក្រអូប មានផ្ទុជារសឆ្ងាញ់ពីសាដូចគ្នានឹងផែនដីពីមុននោះដែរ ។ ពួកសត្វទាំងនោះ នាំគ្នាបរិភោគក្រមរដីយ៉ាងនេះអស់កាលជាយូរអង្វែង, មានសេចក្តីរឹងប៉ឹងក្នុងកាយលើសជាងជាន់មុន ហើយមានពណ៌សម្បុរកាន់តែប្លែកៗ គ្នាទៅទៀត (ខ្លះល្អខ្លះអាក្រក់) ។ គ្រានោះ កើតមានសេចក្តីមើលងាយសម្បុរគ្នាដូចរបៀបមុន ។ ព្រោះតែការណ៍នេះ, ក្រមរដីក៏សាបសូន្យបាត់ទៅទៀត ។ លុះវិនាសក្រមរដីអស់ទៅ ទើបមានវល្លិបទាលតា (ឈ្មោះវល្លិមួយយ៉ាងមានរសផ្អែមឆ្ងាញ់) កើតឡើងសំរាប់ជាចំណីអាហារនៃសត្វទាំងឡាយនោះ, ជាវល្លិមានទំនងដូចជាវល្លិត្រកួន ។ លុះកាលកន្លងយូរអង្វែងទៅ, វល្លិបទាលតាក៏វិនាសសាបសូន្យអស់ទៅទៀត ព្រោះទោសនៃការបេះតែមើលងាយសម្បុរគ្នានោះឯង ។ ក្នុងលើកនេះមានសេចក្តីស្តាយស្រណោះវល្លិបទាលតានោះ នាំគ្នាប្រជុំនឹករកអក្ខរៈប្រាប់ដើមដូចលើកមុន ប៉ុន្តែពុំអាចនឹងយល់សេចក្តីបាន ។

កាលបទាលតាវិនាសបាត់ទៅហើយ ក៏កើតមានស្រូវសាលីឡើងទៀត ជាស្រូវគ្មានកុណ្ឌក គ្មានអង្កាម សស្អាតមានក្លិនក្រអូប មានផ្លែ

ចេញមកជាអង្ករតែម្ដង ។ សត្វទាំងឡាយ បេះយកស្រូវសាលីនោះ
ត្រង់កន្លែងណាមកបរិភោគក្នុងពេលល្ងាច, លុះព្រឹកឡើងត្រង់កន្លែង
នោះក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញដដែល, បើ
បេះក្នុងពេលព្រឹក ដល់ពេលល្ងាច ក៏កើតមានឯង ៗ ដូចដើមវិញដែរ ។
សត្វទាំងនោះ បរិភោគស្រូវសាលីយ៉ាងនេះអស់កាលជាយូរអង្វែង មាន
សេចក្ដីរឹងប៉ឹងក្នុងកាយលើសប្រមាណជាងមុនៗ ទាំងពណ៌សម្បុរ ក៏ប្រែ
ប្លែក ៗ គ្នាដោយច្រើនទៅទៀត ។ ដល់មកត្រង់នេះស្រាប់តែកើតមាន
ភេទស្រីនឹងប្រុសប្រាកដឡើងភ្លាម ជាភេទអាចឲ្យសំគាល់បានថា នេះ
ស្រី នោះប្រុស ដោយមានកិនការផ្សេងពីគ្នា ។ គ្រានោះ ស្រីសំឡឹង
មើលប្រុស ៗ សំឡឹងមើលស្រី ទៅវិញទៅមកដរាបតែហួសពេលវេលា ។
ព្រោះអាស្រ័យការសំឡឹងមើលគ្នា ហួសពេលយ៉ាងនេះ តម្រេកក៏កើត
ឡើង សេចក្ដីសោប់សល់ព្រោះតម្រេក ក៏ប្រែផ្ដុំចុះក្នុងកាយរៀងរាល់
ខ្លួន ។ បន្ទាប់ពីនេះមក, សត្វទាំងនោះបាននាំគ្នា ផ្ដើមចុនកិច្ចកាម
ចំណាន់ ។ សម័យនោះ ពួកសត្វដែលបានឃើញគ្នាឯងកំពុងប្រព្រឹត្ត
បទអសទ្ធម្មដូច្នោះ ខ្លះគេបដីបាចទៅលើ ខ្លះគេបផេះឬសម្រាមផ្សេង ៗ
បាចបោះទៅដោយមានពាក្យជេរប្រទេចថា " នែសត្វចង្រៃ ! លាញ
ទៅ ! នែសត្វចង្រៃ ! អន្តរធានហិនហោចទៅ ! ហេតុម្ដេចក៏បានជា
សត្វឯងហ៊ានមកធ្វើបាបសត្វដូចគ្នាយ៉ាងនេះ" ។ សត្វទាំងឡាយនាំគ្នាទឹក
តេអក្ខរៈដែលជាច្បាប់ចាស់នោះឯង ប៉ុន្តែពុំអាចនឹងយល់សេចក្ដីបាន ។

សម័យនោះ ពួកសត្វដែលបានប្រព្រឹត្តនូវមេថុនធម្ម មិនហ៊ានទៅក្នុងពួកក្រុមជាមួយនឹងគេទេ គេរាំងគេចេញទៅនៅដោយឡែក អស់កាលចំនួនបីខែក៏មាន ពីរខែក៏មាន ព្រោះគេទុកពួកសត្វបែបនោះថាជាអ្នកមិនត្រឹមត្រូវល្អ ។ លុះកន្លងកាលយូរ ៗ ទៅ ការពេញចិត្តក្នុងអសទ្ធម្មនោះក៏កាន់តែកើតឡើងដល់បណ្ដាសត្វទាំងនោះតាមលំដាប់ ដរាបដល់មានសេចក្ដីអៀនខ្មាសគ្នាឯងក្នុងទីវាល ទើបបានផ្ដើមធ្វើផ្ទះសម្បែង ដើម្បីបិទបាំងការពុំគប្បីនោះឯង ៗ គ្រានោះ មានសត្វមួយជាអ្នកខ្ជិលច្រអូស បានគិតឃើញថា ការដែលបេះបួតស្រូវសាលីយកមកបរិភោគក្នុងមួយថ្ងៃពីរដង គឺបេះពេលព្រឹកសម្រាប់បរិភោគតែពេលព្រឹក បេះពេលល្ងាចសម្រាប់តែពេលល្ងាចដូច្នេះ ជាការនាំឲ្យលំបាកខ្លួនឥតប្រយោជន៍ គួរតែយកតែម្ដងហើយទុកសម្រាប់បរិភោគបានពេលល្ងាចផង ព្រឹកផង ទើបស្រួល ៗ សត្វនោះលុះគិតឃើញដូច្នោះហើយក៏បានទៅបេះយកស្រូវសាលីតែម្ដងក្នុងពេលល្ងាច ហើយទុកបរិភោគឲ្យបានដល់ពេលព្រឹកផង ៗ តមក សត្វដទៃទៀត បានយកតម្រាប់សត្វនោះតៗគ្នា ព្រោះឃើញថាជាការស្រួលមែន ៗ ប៉ុន្តែការទៅនាំយកស្រូវសាលីនោះចេះតែឡើងៗឡើងជាដរាប គឺសត្វដំបូងយកពីល្ងាចទុកបរិភោគដល់ព្រឹក ពួកទី ២ យកតែម្ដង ទុកបរិភោគបានពីរថ្ងៃ ពួកទី ៣ យកតែម្ដង ទុកបរិភោគបាន ៤ ថ្ងៃ ពួកទី ៤ យកតែម្ដង ទុកបរិភោគ

បាន ៨ ថ្ងៃ ៗ កាលពួកសត្វទាំងនោះ មានការបេះសន្សំទុកយ៉ាងនេះ ហើយ កុណ្ឌកក៏រុំព័ទ្ធអង្ករ ទាំងអង្កាមគឺសម្បកស្រូវក៏រុំព័ទ្ធអង្ករដែរ, សម្បកនៃទីដែលពួកសត្វទាំងនោះបានច្រូតហើយ ក៏លែងមានស្រូវដុះឡើងវិញ, កន្លែងខ្លះមានដុះដែរ តែមិនបានពេញដូចដើម គឺដុះល្បោលៗ មួយគុម្ព ៗ ត្រង់នេះខ្លះ ត្រង់នោះខ្លះ ។

កាលបានឃើញហេតុប្រែប្រួលដូច្នេះ, ពួកសត្វទាំងនោះមកប្រជុំគ្នា ត្អូញត្អែរថា នែគ្នាយើងអើយ! ធម៌ដ៏លាមក បានកើតមានប្រាកដក្នុងក្រុមយើងហើយ ព្រោះកាលដើមដំបូង ពួកយើងកើតឡើងដោយឈានចិត្ត មានបីតិជាអាហារ មានពន្លឺភ្លឺចេញអំពីខ្លួន ត្រាច់ទៅតាមអាកាសបានអស់កាលជាអង្វែង ៗ តមកពួកយើងបរិភោគផែនដីមានរសផ្អែមអណ្ដែតលើទឹក ពន្លឺភ្លឺចេញអំពីខ្លួនក៏សាបសូន្យបាត់ទៅ បន្ទាប់ពីនោះមកទៀតកើតមានសេចក្ដីប្រែប្រួលផ្សេង ៗ ដូចខាងក្រោមនេះ :

– កើតព្រះច័ន្ទនិងព្រះអាទិត្យ រហូតដល់ខែឆ្នាំ, ផែនដីមានរសផ្អែមក៏សាបសូន្យបាត់ទៅ ;

– កើតក្រមរដីមានរសឆ្ងាញ់ សម្រាប់ពួកយើងអស់កាលយូរ ហើយវិនាសបាត់ទៅទៀត ;

– កើតវល្លិបទាលតាដ៏មានឱជារសអស់កាលជាអង្វែងហើយបាត់សូន្យទៅវិញ ;

– កើតស្រូវសាលី គ្មានកុណ្ឌក គ្មានអង្កាម មានផ្លែពេញជាអង្ករតែម្ដង ។

តទៅនេះ ស្រូវសាលីកើតឯងនោះប្រែខ្លួនទៅជាមានកុណ្ឌក មានអង្កាម ថែមទាំងលែងដុះពេញបរិបូណ៌ដូចពីដាន់មុនទៀតផង, ទាំងនេះមកពីពួកយើងមានអកុសលធម៌ណាមកចូលលុកលុយក្នុងខ្លួន ។ បើដូច្នោះគួរតែពួកយើងចែកស្រូវសាលីគ្នា ហើយធ្វើព្រំខណ្ឌបោះទាំងដោយឡែកៗពីគ្នាទើបស្រួល ។ លុះបានពិគ្រោះគ្នាដូច្នោះហើយ សត្វទាំងឡាយក៏បានបែងកាត់ស្រូវសាលីចែកគ្នា ហើយបោះព្រំខណ្ឌដោយខ្លួនៗ ។

គ្រានោះ មានសត្វមួយជាអ្នកចិលខ្ជិល បានលាក់សំចែបំណែករបស់ខ្លួនទុក ហើយទៅលួចយកចំណែករបស់អ្នកដទៃដែលគេមិនបានយល់ព្រមឲ្យមកបរិភោគខ្លួនឯង ។ សត្វទាំងឡាយបានចាប់សត្វនោះមកស្ដីបន្ទោសកុំឲ្យធ្វើអំពើបែបនោះទៀត ។ សត្វនោះទទួលព្រមថាកន្លងពាលតែមួយភ្លែតប្រែហើយទៅលួចចំណែករបស់គេជាគំរប់ពីរដងបីដងទៀត ។ សត្វទាំងឡាយ ចាប់បានលើកក្រោយនេះ អត់ទ្រាំពុំបាន ព្រោះប្រដៅមិនស្ដាប់ ខ្លះក៏ទះគប់សត្វនោះ, ខ្លះវាយនឹងដុំដី, ខ្លះវាយនឹងដំបងព្រនង់ផ្សេងៗ ទាល់តែទ្រមខ្លួន ។ ចាប់តាំងពីកាលនោះជាដើមមក ការលួចទ្រព្យគេក៏កើតប្រាកដឡើង ទាំងការតិះដៀល - និយាយកុហក

នឹងដាក់អាជ្ញា ក៏កើតមានឡើងដែរ ។ ពួកសត្វទាំងនោះមកប្រជុំគ្នា ត្អូញត្អែរអំពីធម៌ដ៏លាមកដែលកើតឡើង ជាហេតុនាំឲ្យលំបាកសម្រុះសម្រួលគ្នា ក្នុងពេលមានរឿងរ៉ាវដូចខាងលើនេះ ទើបបានមូលមាត់គ្នាសន្មតសត្វមួយដែលមានរូបល្អ មានស័ក្តិធំជាងគេ (គឺព្រះបរមពោធិសត្វនៃយើង) ឲ្យជាអ្នកស្តីបន្ទោសតិះដៀលនិងបណ្តេញពួកសត្វដែលមានកំហុស តាមសមគួរដល់ហេតុ ហើយសត្វទាំងឡាយ ព្រមសុខចិត្តជូនចំណែកស្រូវសាលីជារង្វាន់ដល់សត្វនោះគ្រប់ៗគ្នា ។ សត្វដែលគេសន្មតតាំងនោះ ក៏បានកាន់ការវិនិច្ឆ័យរឿងរ៉ាវផ្សេងៗដែលកើតឡើងម្តងៗ ហើយក៏បានទទួលចំណែកស្រូវសាលីអំពីសត្វដទៃជាធម្មតា ។

ដោយសត្វនោះឯងមហាជននាំគ្នាសន្មត ទើបកើតអក្ខរៈសម្រាប់ហៅជាដំបូងឡើងថា "មហាសម្មតៈ", ដោយបានជាអធិបតីនៃខេត្ត (ស្រែ) ទាំងឡាយ ទើបកើតអក្ខរៈទី ២ ថា "ខត្តិយៈ ខត្តិយៈ", ដោយញ៉ាំងសត្វទាំងឡាយដទៃឲ្យរីករាយពេញចិត្តតាមគុណធម៌ ទើបកើតអក្ខរៈទី ៣ ឡើងថា "រាជា រាជា" ដូច្នេះ ។ អក្ខរៈជាច្បាប់ចាស់បានកើតឡើងដល់ខត្តិយមណ្ឌលនោះ ដោយទំនងយ៉ាងនេះឯង ។ ការកើតឡើងនៃអក្ខរៈដល់ពពួកសត្វទាំងនោះ ដូចគ្នានឹងពួកសត្វដទៃទៀតដែរ មិនមែនខុសគ្នាទេ គឺកើតឡើងដោយធម៌ពិតប្រាកដ មិន

មែនដោយខុសធម៌ទេ ព្រោះធម៌ជាគុណជាតដ៏ប្រសើរបំផុតក្នុងប្រជុំជន
ទាំងបច្ចុប្បន្ននិងបរលោក ។

គ្រានោះឯង មានពួកសត្វខ្លះបានគិតឃើញថា ធម៌ដ៏លាមកច្រើនប្រការមានការលួចទ្រព្យគេជាដើម បានកើតប្រាកដឡើងដល់ចំណោមក្រុមខ្លួនហើយ ពុំគួរនឹងបណ្ដោយឲ្យវាតែកើតថែមឡើងទៀតសោះ ទើបនាំគ្នាបន្សាត់ជម្រះចោលនូវអកុសលធម៌ទាំងនោះចេញ ។ ដោយសត្វទាំងឡាយនោះបានបំបាត់ធម៌អកុសលចោលចេញដូច្នោះ ទើបកើតមានអក្ខរៈទី ១ ឡើងថា "ព្រាហ្មណៈ ព្រាហ្មណៈ", ដោយបានធ្វើជុំរំស្ងឹកនៅក្នុងព្រៃរំលោង គ្មានភ្លើងគ្មានផ្សែងគ្មានត្បាល់អង្រែ ត្រាច់ទៅរកអាហារក្នុងពេលល្ងាចសម្រាប់បរិភោគពេលល្ងាច ក្នុងពេលព្រឹកសម្រាប់ពេលព្រឹក រួចហើយមកសម្ងំសំឡឹងអារម្មណ៍ក្នុងជុំរំស្ងឹករៀងៗខ្លួន ទើបកើតមានអក្ខរៈទី ២ ថា "ឈាយិកា ឈាយិកា", ដោយសត្វពួកខ្លះ ពុំអាចនឹងសំឡឹងអារម្មណ៍ ក្នុងជុំរំស្ងឹកក្នុងព្រៃរំលោងបានដូចគេ ក៏ចូលទៅកាន់ស្រុក-និគមជិតៗ បង្ហាត់បង្រៀននូវគន្ថៈ (វេទមន្ត) ដល់មនុស្សទាំងឡាយ ទើបកើតមានអក្ខរៈទី ៣ ឡើងទៀតថា "អជ្ឈាយិកា អជ្ឈាយិកា" ។ អក្ខរៈជាច្បាប់ចាស់បានកើតឡើងដល់ព្រាហ្មណមណ្ឌលដោយប្រការដូច្នេះឯង ។

(មាឌក)

អក្សរសាស្ត្រជាពន្លឺជាតិ ជាគោលបរិកជាតិ
អក្សរសាស្ត្ររលត់ ជាតិរលត់ ។

## ព្រះរាជប្រវត្តិ

# សម្ដេចព្រះមហាសង្ឃរាជព្រះនាម ទៀង

១៨២៣ - ១៩១៣

(ដកស្រង់ពីសៀវភៅព្រះរាជប្រវត្តិបុព្វបរិយា ដែលតែងឡើងក្នុងពិធីបុណ្យ ថ្វាយព្រះភ្លើង នៅឆ្នាំ ១៩១៤)

ទ្រង់ព្រះកំណើតនៅថ្ងៃសៅរ៍ ៧ កើតខែអាសាឍ ឆ្នាំវកឆស័ក ព.ស. ២៣៦៦ (គ.ស. ១៨២៣) សម្ដេចព្រះមហាសង្ឃរាជាសង្ឃនាយក ព្រះនាមទៀង ជាបុត្រច្បងនៃបិតានាមទិលនិងមាតានាមឡូក ។

ក្នុងព្រះជន្មវស្សាបាន ៨ ឆ្នាំ កុមារទៀងនៅក្នុងសេចក្ដីទំនុកបំរុង របស់មា ១ នាក់ឈ្មោះ តៅ ជាមហាតលិកព្រះបាទសម្ដេចព្រះហរិរក្ស-រាមាឥស្សរាធិបតី កាលគង់នៅជាព្រះអង្គម្ចាស់ដួងនៅឡើយ ។

ព្រះជន្មវស្សាបាន ១១ ឆ្នាំ ក្នុងឆ្នាំមមី ព.ស. ២៣៧៧ (គ.ស. ១៨៣៤) កុមារទៀងបំពេញផ្នួសជាសាមណេរ ហើយបានរៀនព្រះបរិយត្តិធម៌ ក្នុងក្រុងបាងកកប្រទេសសៀម ចេះដឹងមុតមាំជាពេកដល់ព្រះចៅក្រុងសៀម ទទួលស្គាល់រាប់អានយ៉ាងជិតស្និទ្ធ ។

ឆ្នាំរោងឆស័ក ព.ស. ២៣៨៧ (គ.ស. ១៨៤៤) ព្រះជន្មវស្សា បាន ២១ ឆ្នាំ ព្រះបាទសម្តេចព្រះណាំងក្លាវព្រះចៅក្រុងសៀមទ្រង់ព្រះរាជានុញ្ញាតឲ្យសាមណេរទៀង បួសបំពេញឧបសម្បទក្នុងនាគខាន ព្រះរាជទ្រព្យនៅវត្តព្រះស្រីរតនសាស្ដារាម គឺវត្តព្រះកែវមរកតក្រុងបាងកក ។

ឆ្នាំរកាឯកស័ក ព.ស. ២៣៩២ (គ.ស. ១៨៤៩) ព្រះជន្មវស្សា បាន ២៥ ឆ្នាំ ព្រះអាចារ្យទៀងបានធ្វើជាគ្រូបង្រៀនសិស្សគណៈជាច្រើននៅក្រុងបាងកក មាននាមល្បីល្បាញថាជាអ្នកប្រាជ្ញ ១ រូបយ៉ាងជំនាញ ។ គ្រានោះបានចូលទៅថ្វាយព្រះពរលាសម្តេចព្រះណាំងក្លាវ ត្រឡប់មកប្រទេសកម្ពុជាវិញ ព្រះអង្គក៏បានទ្រង់ព្រះរាជានុញ្ញាតតាមបំណង ។ លុះមកដល់ហើយ បានចូលថ្វាយព្រះពរសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះអង្គដួងគង់ព្រះបរមរាជវាំងឧដុង្គមានជ័យ ទ្រង់មានព្រះរាជហឫទ័យសោមនស្សណាស់ បានសូមនិមន្តឲ្យគង់នៅប្រទេសកម្ពុជា ដើម្បីជួយទំនុកបំរុងព្រះពុទ្ធសាសនាឲ្យបានរុងរឿង ដោយទ្រង់មានព្រះរាជសុភអក្សរ ទៅសុំដល់សម្តេចព្រះណាំងក្លាវៗ ក៏ទ្រង់ព្រះរាជានុញ្ញាតតាម ។ ព្រះអាចារ្យទៀងបានទទួលសមណស័ក្តិ ជាព្រះអរិយវង្សអំពីព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី ហើយគង់នៅវត្តប្រាក្ដិឧដុង្គមានជ័យ ។ លុះចំណេរតមកបានឡើងជាព្រះធម្មុត្តម,

ព្រះមហាវិមលធម្ម នឹងព្រះមហាព្រហ្មមុនី បានបង្ហាត់បង្រៀនព្រះរាជវង្សានុវង្ស នូវអស់នាម៉ឺនមុខមន្ត្រី នឹងបណ្ដារាស្ត្រឲ្យបានចេះដឹងក្ដីថ្លាក្នុងព្រះពុទ្ធសាសនាជាច្រើន ។

ឆ្នាំម្សាញ់ នព្វស័ក ព.ស. ២៤០០ (គ.ស. ១៨៥៧) ព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី ទ្រង់លើកព្រះមហាព្រហ្មមុនី ទៀង ព្រះជន្មវស្សា ៣៩ ឲ្យគ្រងទីសម្ដេចព្រះមហាសង្ឃរាជក្រុងកម្ពុជា ។ លុះរំលងពីនោះមកបានមួយឆ្នាំ ដោយទ្រង់មានព្រះដំរិះយល់ច្បាស់នូវចំណេះដ៏ខ្ពង់ខ្ពស់របស់សម្ដេចព្រះមហាសង្ឃរាជ ទៀង ទើបព្រះអង្គទ្រង់តាំងជាស្ដេចសង្ឃពេញទី ហើយបានរៀបពិធីស្រោចទឹកខ្ទស់ទឹកស័ង្ខនៅក្រុងឧដុង្គមានជ័យ មានគោរម្យងារជា **សម្ដេចព្រះមហាសង្ឃរាជាគណាធិបតីសិរីបរមបពិត្រជាសង្ឃនាយកតិលកលោកាចរិយោត្តមបរមមេធសង្ឃជេដ្ឋមហាសង្ឃរាជាធម្មិកវរោត្តមបរមបពិត្រជាមគ្គនាយក សម្រេចកិច្ចអស់ទ្រទូងសង្ឃព្រះរាជាគណៈទាំង ៤ សំរាប់ ។** ក្នុងឆ្នាំនោះ សម្ដេចបានរៀបចំដេញប្រយោគ ព្រះបរិយត្តិបាលីព្រះត្រៃបិដកនឹងរបៀបទេសនាជាដំបូងចំពោះព្រះសង្ឃក្នុងព្រះនគរ តាមព្រះរាជានុញ្ញាតនៃព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី ដែលទ្រង់មានព្រះរាជសទ្ធាដ៏លើសលប់ក្នុងពុទ្ធសាសនា ។

ឆ្នាំម្សាញ់ត្រីស័ក ព.ស. ២៤២៣ (គ.ស. ១៨៨០) ដល់មកក្នុងរាជ្យព្រះបាទសម្ដេចព្រះនរោត្ដម ព្រះចៅក្រុងកម្ពុជាធិបតី ដែលទ្រង់បានសោយរាជសម្បត្តិតពីសម្ដេចព្រះវរបិតាមកនោះ សម្ដេចព្រះមហាសង្ឃរាជទ្រង់ឲ្យរៀបដេញប្រយោគព្រះត្រៃបិដកនៅព្រះបរមរាជវាំងក្រុងភ្នំពេញជាលើកទី ២ ។

ឆ្នាំវកអដ្ឋស័ក ព.ស. ២៤៣៩ (គ.ស. ១៨៩៦) ដោយបានទទួលព្រះរាជឱង្ការព្រះបាទសម្ដេចព្រះនរោត្ដម សម្ដេចព្រះមហាសង្ឃរាជទ្រង់ត្រួតត្រា ការកសាងព្រះឧបោសថវត្តនារាមព្រះកែវមរកតក្រុងភ្នំពេញដរាបដល់ហើយស្រេច ។ បន្ទាប់ពីនោះមកសម្ដេចបានទទួលព្រះរាជឱង្ការត្រួតត្រា ការកសាងព្រះវិហារមួយក្នុងព្រះបរមរាជវាំងចាស់ក្រុងឧដុង្គ នឹងត្រួតត្រាការកសាងព្រះប្រាង្គមួយក្នុងទីវត្តប្រាង្គ ដើម្បីបញ្ចុះព្រះសារីរិកធាតុព្រះសម្ពុទ្ធដែលបានមកពីលង្កាទ្វីប តាំងពីក្នុងរាជ្យព្រះបាទសម្ដេចព្រះហរិរក្សរាមាព្រះអង្គដួង (ការកសាងព្រះប្រាង្គនេះដរាបមកដល់រាជ្យព្រះបាទសម្ដេចព្រះស៊ីសុវត្ថិទើបហើយស្រេច) ។

ក្នុងរាជ្យព្រះបាទសម្ដេចព្រះស៊ីសុវត្ថិនេះ សម្ដេចព្រះមហាសង្ឃរាជបានចាប់ផ្ដើមរៀបចំពិធីដេញប្រយោគ ព្រះបរិយត្តិធម្មជាន់ទៀត ជាលើកទី ៣ នៅវត្តព្រះកែវមរកត ក្រុងភ្នំពេញ ព្រោះការនេះអាក់ខានធ្វើមកជាយូរឆ្នាំហើយ ដោយខ្វះបច្ច័យជាគ្រឿងឧបត្ថម្ភ ។

សម្តេចព្រះមហាសង្ឃរាជទៀង ទ្រង់ចេះព្រះត្រៃបិដក អក្សរសំស្ក្រឹត និងអក្សរបុរាណយ៉ាងជ្រៅជ្រះ ហើយទ្រង់បានរៀបរៀងសាស្ត្រផ្សេងៗជាច្រើន មានព្រះបឋមសម្ពោធិ បាតិមោក្ខប្រែនិងសាស្ត្រត្រៃភូមិជាដើម ។

សម្តេចទ្រង់សោយទិវង្គតនៅថ្ងៃព្រហស្បតិ៍ ២ កើតខែអស្សុជ ឆ្នាំឆ្លូវបញ្ចស័ក ព.ស. ២៤៥៦ (២-១០-១៣) វេលាម៉ោង ១២ និង ៤០ នាទីអាធ្រាត្រ ក្នុងព្រះជន្មវស្សាគំរប់ ៩០ ដោយព្រះរោគជរាពាធនៅដំណាក់វត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

---

## ស្នាដៃសន្ធរម៉ុក

(តពីសៀវភៅលេខ ១ ទំព័រ ២១)

ថ្ងៃថ្មើមបង្គន់ បង្គយមិនខ្ពន់ មិនខ្ពតទេត្រង់យន់ នេត្រ
នាងស្រស់ស្រួល ដូចនីលបវណ៌ បរនាគល្អតល្វៃ ល្អតល្ហេនតូច
ល្មម ៗ ភ័ព្វបងបានបួន បានចួបនឹងសួន សួនបង្អព្រម ព្រម
ចិត្តស្នេហ៍ស្នង បងប៉ងនឹងថ្នម ថ្នមមាសមុំម៉ម ម៉មម៉ៃបែកបាត់ ៗ
បាត់ក៏រម្យរ័ក រ័ករូមនៃបក្សក អ្នកមាសវរលក្ខណ៍ លក្ខណ៍ល្អងមេត្រី
ដោយក្តីស្មោះស្ម័គ្រ ស្ម័គ្រស្មើយសសក្តិ សក្តិសមជាគូ ៗ

## ការសាងអាយតនៈ (តមកទឹងចប់)

(ការកសាងអាយតនៈនេះ យើងបានចុះផ្សាយហើយក្នុងមិត្តសាលាបាលីឆ្នាំ ១៩៥០ ពីលេខ ១០ ដល់លេខ ១១ ។ ក្នុងលេខ ១១ នោះបានចុះផ្សាយអស់ត្រឹមការកសាងអណ្ដាត ហើយត្រង់ចំណងជើងខាងដើម យើងបានសរសេរដោយភាន់ច្រឡំថា "តមកទឹងចប់" ។ រឿងនេះមិនទាន់ចប់ទេ នៅមានការកសាងកាយនឹងចិត្តទៀត ព្រោះអាយតនៈមាន ៦ គឺ ភ្នែក, ត្រចៀក, ច្រមុះ, អណ្ដាត, កាយ, ចិត្ត. ។ ដូច្នេះ មិត្តសាលាបាលីសូមអភ័យទោសអំពីលោក តែ-ជូនជាអ្នកនិពន្ធ នឹងលោកអ្នកអានទាំងឡាយ) ។

### សាងកាយ

ស.– កាយ គេត្រូវកសាងដូចម្ដេច?

ឆ.– កាយ គេត្រូវកសាងដោយការហាត់រៀនធ្វើការផ្សេងៗ ឲ្យស្ទាត់ជំនាញឡើង ដូចយ៉ាងរៀនសរសេរអក្សរ រៀនជាងដែក-ជាងឈើ-ជាងមាស-ប្រាក់ ជាងគ្រឿងចក្រ, ជាងដេរខោអាវជាដើម បានសេចក្ដីថា ត្រូវរៀនវិជ្ជាហត្ថកម្មផ្សេងៗ ឲ្យបានស្ទាត់ជំនាញក្នុងមុខការណាមួយ ដើម្បីញ៉ាំងជីវភាពនៃខ្លួនឲ្យប្រព្រឹត្តទៅដោយប្រពៃ ព្រោះនៅក្នុងស្ថានមនុស្សនេះ មិនមែនដូចស្ថានទេវតាទេ ។ គ្រឿងឧបភោគនឹងគ្រឿងបរិភោគទាំងឡាយ សុទ្ធតែកើតឡើងដោយកំឡាំងហត្ថកម្ម

ទាំងអស់ បើគ្មានវិជ្ជាខាងហត្ថកម្មបរិបូរទេ មនុស្សយើងមិនអាចនឹងញ៉ាំងជីវិតរបស់ខ្លួនឲ្យថ្លៃថ្នូរបានឡើយ បើទុកជាមានសរីរាវយវៈពេញលក្ខណៈយ៉ាងណា ក៏មិនអាចប្រើការបានចំពោះការងារទាំងឡាយដែលកើតឡើងដោយអាស្រ័យការហាត់រៀននោះឡើយ គឺប្រើបានទៅតាមសភាវៈជាធម្មតានៃសរីរាវយវៈដែលសំណាងអំពីអតីតជាតិចែងមក គឺថាគ្រាន់តែ បេះដក, ដើរ, ឈរ, អង្គុយ, ចាប់, កាន់, លើក, ដាក់ ប៉ុណ្ណោះជាដើម ដែលជាកាតព្វកិច្ចនៃធម្មជាតិរបស់ខ្លួន ៗ បើយើងមិនចំរើនប្រែប្រួលធ្វើចំណោះធម្មតានៃកាយនោះ ឲ្យវិសេសឡើងដោយសិល្បៈឯណានីមួយ សំរាប់ប្រើប្រាស់ក្នុងលោកនេះទៅតាមសភាពបុរស-ស្ត្រីទេ ឈ្មោះថាកាយឥតសំណាង ៗ

រឿងកសាងកាយឲ្យបានប្រកបដោយសិល្បកម្មនេះ អស់លោកអ្នកធ្លាប់បានដឹង-ឮ-ឃើញហើយ ដែលគេហៅថា "ស្នាដៃ" ដូចជាប្រាសាទនគរវត្តក្តី គ្រឿងម៉ាស៊ីនទាំងឡាយក្តី គេហស្ថាន, គ្រឿងឧបភោគនិងគ្រឿងបរិភោគទាំងឡាយក្តី ដែលមាននៅតាំងពីសម័យបុរាណឬកើតឡើងក្នុងសម័យនេះ មិនមែនកើតឡើងដោយកំឡាំងទេពនិម្មិតទេ គឺដោយកម្លាំងហត្ថកម្មនៃមនុស្សជាតិទាំងអស់ ៗ ដូច្នេះ ការហត្ថកម្មក្តី វត្ថុដែលកើតអំពីហត្ថកម្មក្តី គ្មាននរណាមួយអាចបដិសេធថា "មិនត្រូវការ" បានទេ ៗ បើនិយាយដោយរួបរួម ក្នុងស្ថានមនុស្សនេះ

ជីវភាពនៃមនុស្សលោកមិនអាចតាំងនៅប្រពៃបាន ដោយប្រាសចាកវត្ថុនិងកិច្ចការនៃហត្ថកម្មឡើយ ។ ប្រសិនជាប្រទេសណាមួយក្នុងសកលលោកនេះ ប្រាសចាកហត្ថកម្មនិងវត្ថុដែលកើតអំពីហត្ថកម្មហើយ ប្រទេសនោះស្ទើរតែរកមនុស្សអាស្រ័យនៅគ្មាន ព្រោះហេតុនៃសេចក្តីឃ្លៀងឃ្លាតសុខភាព របស់មនុស្សជាតិដែលហូរមកតាមប្រឡាយ គឺវត្ថុដែលកើតអំពីហត្ថកម្មឬកិច្ចការនៃហត្ថកម្ម ។

មួយទៀត សកលលោកនេះ ជាសង្គមមួយ ហៅថា "សង្គមមនុស្ស" ។ សង្គមនេះ ពពួកមនុស្សត្រូវការប្រស្រ័យគ្នាទៅវិញទៅមកដោយវត្ថុ និងកិច្ចការនៃហត្ថកម្មជានិច្ច ។

ពាក្យថា សង្គម ចែកចេញជាប្រភេទដូចតទៅនេះ :—

១ – មនុស្សសង្គម សំដៅយកស្ថានមនុស្សទាំងមូល

២ – ទេវសង្គម សំដៅយកស្ថានទេវតាគ្រប់ជាន់

៣ – ព្រហ្មសង្គម សំដៅយកស្ថានព្រហ្មគ្រប់ជាន់

៤ – តិរច្ឆានសង្គម សំដៅយកពពួកតិរច្ឆាន

៥ – បេតសង្គម សំដៅយកពពួកប្រេត

៦ – អសុរកាយសង្គម សំដៅយកពពួកអសុរកាយ

៧ – នេរយិកសង្គម សំដៅយកពពួកសត្វនរក ។

បណ្តាសង្គមទាំងឡាយនេះ សូមអធិប្បាយតែអំពីសង្គមទី ១

(មនុស្សសង្គម) គង់អស់លោកអ្នកជ្រាបបាន ដល់សង្គមឯទៀតៗ ដោយងាយ ព្រោះពាក្យថា "សង្គម" នេះ បានសេចក្ដីថាពួក, បក្ស, ក្រុម ឬ បន ។

មនុស្សសង្គម ចែកចេញជា ៥ យ៉ាង :-

១ -- មហាសង្គម បានដល់ការរួបរួមស្ថានមនុស្សទាំងមូល;

២ – ទ្វីបសង្គម បានដល់ពពួកមនុស្សដែលចែកចេញជា ៥ ផ្នែក គឺ: អាស៊ី, អឺរ៉ុប, អាហ្វ្រិក អាមេរិក, អូស្ត្រាលី (ក្នុងមួយៗ ហៅថា សង្គម ១) ។

៣ – សមាគតសង្គម បានដល់ប្រទេសនានាដែលរួបរួមចូលជាសហរដ្ឋនៃប្រទេសណាមួយ ដូចជាសហរដ្ឋអាមេរិក, សហរដ្ឋអង់គ្លេស, សហរដ្ឋបារាំងសែស, សហរដ្ឋរុស្ស៊ីជាដើម ។

៤ – បច្ចេកសង្គម បានដល់ប្រទេសនីមួយៗ ដែលមានជាតិមនុស្សជាម្ចាស់នៃប្រទេសតែមួយ ដូចជាប្រទេសខ្មែរ ជាតិខ្មែរ, ប្រទេសបារាំង ជាតិបារាំង ប្រទេសណាជាតិនោះ ។

៥ – អន្តរសង្គម បានដល់ពួកឬក្រុមនៃមនុស្សដែលនៅក្នុងប្រទេសនីមួយៗ មានសីលធម៌ អាចារធម៌, ប្រវេណីធម៌និងកិច្ចការជាសមានុគតិកិរិយា ។

ដើម្បីកសាងសង្គមទាំងនោះក្ដី ដើម្បីនឹងធ្វើជីវភាពរបស់ខ្លួនដែលនៅក្នុងសង្គមទាំងនោះឲ្យបានចំរើនឡើងក្ដី មនុស្សជាតិត្រូវតែខំប្រឹង

ប្រែងហាត់រៀនវិជ្ជាខាងហត្ថកម្មតាមសម័យ ឲ្យបានចេះស្ទាត់ជំនាញឡើង មិនត្រូវដេកចាំសំណាង ដែលខ្លួនមិនបានកសាងនោះឡើយ ។

អ្នកប្រាជ្ញទាំងឡាយបានពោលថា "អ្នកណាមួយ ទោះជាបុរសក្តី ស្រ្តីក្តី កាលបើមិនចេះប្រកបកិច្ចការតាមសភាពរបស់ខ្លួន អ្នកនោះទុកស្មើមនុស្សកំបុតដៃកំបុតជើង" ដោយហេតុថា ដៃនិងជើងនៃអ្នកនោះ គឺសាមីខ្លួនប្រើប្រាស់ឲ្យសមតាមវត្ថុបំណងមិនបាន ប្រែត្រឡប់ទៅជាមានវិប្បដិសារៈវិញ ។ ឯផលប្រយោជន៍ ដែលហូរហូរមកតាមដៃ-ជើងរបស់ខ្លួនក៏រីងស្ងួត ដូចជាប្រឡាយទឹកក្នុងរដូវប្រាំង ។ ហេតុដូច្នេះ ត្រូវតែយើងខំកសាងដៃ-ជើងយើងឲ្យគួរដល់ការងារ ដែលប្រាសចាកទោសជាបច្ចុប្បន្ន និងបរលោក ទើបហៅថាកាយមានសំណាង ។

## សាងចិត្ត

កាយគុណៈទាំង ៤ ដែលបានរៀបរាប់មកហើយខាងលើ មិនមែនសំរេចការទៅបាន ដោយឥតមានចិត្តចូលទៅអាស្រ័យផងទេ ។ ចិត្តនេះមានភ្នាក់ងារជាអ្នកសន្សំទុកនូវអារម្មណ៍ផង ជានាយកលើកាយគុណៈទាំងឡាយនោះផង ។ ចិត្តនេះ មានភ្នាក់ងារជាអ្នកចាត់ចែងការ ៣ នាក់ គឺ: ចេតសិក ១ វិញ្ញាណ ១ សញ្ញា ១ ។ បណ្តាភ្នាក់ងារទាំង ៣ នាក់នេះ "សញ្ញា" គ្រាន់តែជាអ្នកស្គាល់នូវអារម្មណ៍ថាជា "នេះ" "នោះ" ថា "ដូច្នេះ" "ដូច្នោះ" ហើយប្រគល់ឲ្យមកវិញ្ញាណៗជាអ្នក

ពិនិត្យសង្កេតនូវអារម្មណ៍ទាំងនោះ ឲ្យឃើញច្បាស់ប្រាកដថា: ពិត ដូច្នេះ ដូច្នោះ មែនឬមិនមែន ។ កាលបើញាណឃើញច្បាស់ហើយ ក៏ប្រគល់មកឲ្យចេតសិក ។ ក៏ត្រិះរិះដេញដោលរកហេតុ-ផលនៃការម្មណ៍ទាំងនោះទៀត ដើម្បីនឹងប្រគល់ការមកឲ្យចិត្តជាមេធំបំផុត ចាំទទួលអនុម័តចំពោះអារម្មណ៍ទាំងឡាយ ដែលហូរចូលមកតាមទ្វារណាមួយ នឹងចាត់ប្រើអាយតនៈទាំងឡាយនោះ ឲ្យប្រតិបត្តិការទៅតាមមុខក្រសួងរបស់ខ្លួន ។ ដូច្នេះបានជាត្រូវកសាងចិត្តឲ្យប្រកបដោយគុណសម្បត្តិ ដែលអាចនឹងទទួលចាត់ចែងប្រើប្រាស់អាយតនៈទាំងឡាយឲ្យបានផលប្រយោជន៍ ។

ស.— ការកសាងចិត្តឲ្យមានសមត្ថភាពដូច្នេះ តើត្រូវធ្វើដូចម្ដេច?

ឆ.— ការកសាងចិត្តឲ្យស្ទាត់ជំនាញក្នុងវិធីត្រួតត្រា - ឬប្រើប្រាស់អាយតនៈណាមួយឲ្យបានផលនោះ លុះតែយើងខំប្រឹងរៀនសង្កេតមើលឲ្យឃើញច្បាស់នូវហេតុ-ផល, ជាអតីត-បច្ចុប្បន្ន-អនាគត ដែលប្រព្រឹត្តទៅតាមកំឡាំងនៃការចាត់ចែងរបស់គតិបណ្ឌិត មិនមែនយើងអាចធ្វើបានទៅតាមកម្លាំងចិត្តធម្មតានោះទេ ។

ស.— ដូចម្ដេចដែលហៅថា "ចិត្តធម្មតា ?"

ឆ.— ចិត្តនៃអ្នកដែលមិនបានរៀន-សូត្រឲ្យមានចំណេះវិជ្ជាណាមួយនៅក្នុងខ្លួន ជាគោលសំរាប់ស្រាវជ្រាវពិចារណារិះរកកុសល ឬ

របៀបបែបផែនណាមួយដែលជាគ្រឿងធ្វើខ្លួនឲ្យបានចំរើន ដោយឧបាយនៃប្រាជ្ញា, ហៅថា "ចិត្តធម្មតា" ។

ការកសាងចិត្តនេះជាការក្រៃក្រៃលែង លុះណាតែមុនដំបូងបានរៀនវិជ្ជាផ្សេងៗ ឲ្យចេះចាំស្ទាត់ រួចហើយយកវិជ្ជាទាំងនោះ មកប្រើការឲ្យស្ទាត់ជំនាញ បើកាលណាបានស្ទាត់ហើយ យើងត្រូវតាំងចិត្តដូចម្តេចឲ្យខ្លួនយើងមានមុខឆ្ពោះទៅរកសេចក្តីសុខ-ចំរើន ក្នុងបច្ចុប្បន្ន នឹងបរលោក ។ ការដែលធ្វើខ្លួនឲ្យបានចំរើននេះមកតែអំពីចិត្ត ព្រោះចិត្តជាប្រធានលើសិល្បៈគោត្រទ្រព្យ ញាតិ-មិត្តនឹងវង្សត្រកូល ។ កាលបើចិត្តចុះស៊ប់ទៅក្នុងអំពើវិនាសអស់កាលជានិច្ចហើយ ទោះបីអ្នកនោះមានសិល្បពូកែ មានទ្រព្យច្រើននឹងមានញាតិមិត្តជួយច្រើនយ៉ាងណាក៏ដោយ ឬមានជាតិត្រកូលខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ ក៏គង់ធ្លាក់ទៅជាមនុស្សថោកទាបពុំខាន ។

អ្នកប្រាជ្ញទាំងឡាយបានសំដែងថា ចិត្តនេះបើប្រៀបដោយកម្លាំងគ្មានអ្វីខ្លាំងស្មើ, បើប្រៀបដោយសន្ទុះ គ្មានអ្វីលឿនជាងទេ ។ ចិត្តនេះជាធម្មជាតិ ១ ដែលគេទូន្មានបានដោយកម្រណាស់ ។

ការកសាងចិត្តមានទំនងតែមួយ គឺវៀរបង់គ្រឿងវិនាសទាំងឡាយដែលអ្នកប្រាជ្ញបានពោលទុកក្នុងក្បួនច្បាប់ផ្សេងៗ ឬប្រព្រឹត្តតាមដំបូន្មានចាស់ព្រឹទ្ធាចារ្យទាំងឡាយ ដែលបានប្រៀនប្រដៅទៅតាមប្រវេណីនៃអ្នកដែលបានទទួលសេចក្តីចំរើនអំពីកិច្ចប្រតិបត្តិដ៏ប្រសើរណាមួយ ។

លក្ខណៈដែលនឹងធ្វើចិត្តឲ្យជាអ្នកប៉ិនប្រសប់ ក្នុងការពិនិត្យនូវអារម្មណ៍ទាំងឡាយជា អតីត-បច្ចុប្បន្ន-អនាគតនេះ ជាការៈមួយយ៉ាងធ្ងន់បំផុត នឹងរកអ្វីប្រៀបផ្ទឹមឲ្យស្មើពុំបាន ដោយហេតុថា អារម្មណ៍ទាំងឡាយ ដែលជាទីត្រូវការដល់ចិត្តរបស់បុថុជ្ជន មិនសូវជាអារម្មណ៍ដែលប្រាសចាកសេចក្ដីវិនាសឡើយ ព្រោះចិត្តរបស់បុថុជ្ជនសុទ្ធតែប្រកបដោយលោភៈ ទោសៈ មោហៈ ដែលជាមេវិនាសយ៉ាងធំបំផុត នៅក្នុងខន្ធសន្ដានៃសត្វលោក ម៉្លោះហើយរូបារម្មណ៍ក្ដី សទ្ទារម្មណ៍ក្ដី គន្ធារម្មណ៍ក្ដី រសារម្មណ៍ក្ដី ផោដ្ឋព្វារម្មណ៍ក្ដី ធម្មារម្មណ៍ក្ដី ដែលពួកបុថុជ្ជន ត្រូវការដោយក្រៃលែងនោះ បំពោះតែអារម្មណ៍ ដែលប្រកបដោយកិលេស ៗ

ប៉ុន្ដែ បើពោលដោយនិយមតាមកាមាវចរភូមិវិញ ចិត្តដែលគេបានទូន្មានឲ្យវៀរបង់នូវសេចក្ដីវិនាស ដែលជាគតិលោកនឹងគតិធម៌បានដោយម៉ត់ចត់ហើយ ឈ្មោះថាជាចិត្តមានសំណាង ៗ ហេតុដូច្នេះ នរជនប្រុស-ស្រីគប្បីដឹងឲ្យច្បាស់ប្រាកដថា យើងគ្មានអ្វីនឹងអាងឲ្យពូកែស្មើនឹងចិត្តរបស់យើងទេ កាលបើចិត្តយើងចុះស៊ប់ទៅក្នុងសេចក្ដីវិនាសហើយ មិនត្រូវសង្ស័យថា យើងនឹងបានតាំងនៅក្នុងសេចក្ដីចំរើនដោយគុណសម្បត្តិឯណានីមួយឡើយ ព្រោះវត្ថុទាំងអស់សុទ្ធតែមានចិត្តជាប្រធាន ៗ

ដើម្បីនឹងទប់ចិត្តកុំឲ្យធ្លាក់ចុះទៅក្នុងសេចក្ដីវិនាសនោះ ត្រូវរក្សាធម៌ប្រាំពីរយ៉ាង គឺ ខន្ដី សេចក្ដីអត់ទ្រាំមិនធ្វើអំពើអាក្រក់ ១ សោរច្ច

សេចក្ដីស្ងប់នឹងអំពើអាក្រក់ ១ សតិ ការរឮកឃើញផលនៃសេចក្ដីអាក្រក់ ១ សម្បជញ្ញៈ ការដឹងខ្លួនក្នុងពេលមុននឹងធ្វើនូវអំពើអាក្រក់ ១ ហិរិ សេចក្ដីខ្មាសចំពោះអំពើអាក្រក់ ១ ឱត្តប្ប សេចក្ដីក្ដៅក្រហាយចំពោះអំពើអាក្រក់ ១ សំវរៈ បិទខ្ទប់មិនឲ្យអំពើអាក្រក់ជ្រៀតជ្រែកចូលមកក្នុងសន្ដានចិត្តបាន ១ ។

កាលបើបានកសាងអាយតនៈទាំង ៦ ឲ្យបានបែបបទតាមវិធីដូចបានពោលហើយនេះ ទើបបានឈ្មោះថាជាអ្នកមានសំណាងពេញលក្ខណៈ ព្រោះថា អ្នកមានសំណាងដ៏មួយ ៗ មិនមែនដេកចាំព្រេងវាសនាអំពីអតីតទេ ស្ទុះតែខំប្រឹងកសាងអាយតនៈក្នុងបច្ចុប្បន្ននេះឲ្យបានស្អាតល្អទាំងអស់ ។

ឯសំណាងអំពីអតីតគ្រាន់តែជាហេតុឬជាពូជការប៉ុណ្ណោះ ឧបមាដូចជាពូជនៃរុក្ខជាតិ តិណជាតិទាំងឡាយដែលមានធម្មជាតិសំរាប់ដុះដាលលូតលាស់តាំងនៅប្រាកដហើយ តែបើយើងមិនយកទៅសាបព្រោះ ឬដាំនៅលើផែនដី ដែលមានដីជាតិទេ រុក្ខជាតិ ឬតិណជាតិទាំងឡាយនោះ ក៏មិនអាចនឹងដុះដាលលូតលាស់ឡើងបានឡើយ ។

រឿងសំណាងនេះ មានបញ្ហាជាប្រវេណីថា បើទុកជាខំប្រឹងប្រែងយ៉ាងណាក៏ដោយ តែគ្មានបុណ្យអំពីអតីតជាតិទេ ក៏មិនអាចនឹងទៅជាមនុស្សខ្ពង់ខ្ពស់បានឡើយ ។ បញ្ហានេះ យើងអាចដោះស្រាយដោយន័យដូច្នេះ :—

១ – អ្នកដែលបានកើតជាមនុស្សពេញលក្ខណៈហើយ ប្រកបដោយតែហេតុជាន់ខ្ពស់ ហៅថាអ្នកមានបុណ្យអំពីអតីតជាន់ខ្ពស់ ។

២ – អ្នកដែលបានកើតជាមនុស្សហើយ ប្រកបដោយតែហេតុមធ្យម ហៅថា អ្នកមានបុណ្យអំពីអតីតជាមធ្យម ។

៣ – អ្នកដែលបានកើតជាមនុស្សហើយ ប្រកបដោយទុហេតុ ហៅថា អ្នកមានបុណ្យអំពីអតីតយ៉ាងទន់ខ្សោយ ។

បណ្ដាអ្នកមានបុណ្យទាំង ៣ នាក់នេះ ត្រូវតែកសាងអាយតនៈថែមទៀត ទើបអាចទទួលផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់បាន ។

បុគ្គលទាំង ៣ ពួកនេះ គ្មាននរណាអាចមើលស្គាល់បានថា អ្នកនេះមានឋានៈត្រឹមប៉ុណ្ណេះ អ្នកនោះមានឋានៈត្រឹមប៉ុណ្ណោះបានឡើយ សូម្បីតែមាតា-បិតាបង្កើត ក៏មិនអាចទាយត្រូវដែរ, លុះណាតែការកសាងអាយតនៈអស់រយៈវេលាត្រឹមណា ទើបអាចទាយថា "ត្រឹមប៉ុណ្ណេះ, ត្រឹមប៉ុណ្ណោះ" បាន ។ ព្រោះថា ហេតុទាំង ៣ នេះជាធម្មជាតិ ១ យ៉ាងកំបាំងបំផុត ហើយមានប្រាកដនៅក្នុងរូបប្រុស ស្រីគ្រប់ៗគ្នា ។ ឧបមាដូចជាពេជ្របុស្សរ័ត្ន លុះណាតែច្នៃថែមទៀត ទើបមានពន្លឺរស្មីល្អរុងរឿងទៅបាន ។ ពេជ្រនិងត្បូងទាំង ២ នេះ កាលបើគេឃើញច្បាស់ថាមានពន្លឺហើយ ហេតុអ្វីបានជាត្រូវច្នៃថែមទៀត?

ចុះមនុស្សយើងដែលគេមិនស្គាល់ថាជាអ្នកមានឋានៈត្រឹមប៉ុណ្ណា ហេតុអ្វីក៏មានមនុស្សចំពូកខ្លះ មិនព្រមកសាងខ្លួនឲ្យបានជាអ្នកមាន

សំណាងឡើង? ។ ក្នុងអតីតកាលឬក្នុងបច្ចុប្បន្នកាលនេះ អ្នកណាមួយដែលមិនបាច់កសាងអាយតនៈ ហើយស្រាប់តែបានទៅជាអ្នកមានសំណាងតើមានឬទេ? ។

ត្រង់នេះ សូមបញ្ជាក់ថា សូម្បីពពួកព្រហ្មក្តី ពពួកទេវតាក្តី ពពួកព្រះអរហន្តទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើមក្តី ក៏មិនអាចនឹងទទួលផលដ៏ជាទិព្វនៅក្នុងព្រហ្មលោកឬក្នុងទេវលោក ពុំនោះសោតនូវវិមុត្តិរសនៃព្រះនិព្វាន ដោយមិនបាច់កសាងបានឡើយ គឺថាអ្នកទាំងឡាយនោះ សុទ្ធតែខំកសាងទាន, សីល, ភាវនា, ឬសីល សមាធិ បញ្ញា ដោយសេចក្តីព្យាយាមសេចក្តីលះបង់ សេចក្តីតស៊ូគ្មានគិតដល់សេចក្តីនឿយលំបាកនៃខ្លួន ៥ ឡើយ ដូចកាលព្រះសម្មាសម្ពុទ្ធកើតក្នុងបច្ឆិមជាតិដែលមានបារមីចាស់ក្លាហើយក៏គង់ព្រះអង្គខំកសាងទុក្ករកិរិយា អស់ ៦ វស្សាទៀត ទើបបានត្រាស់ជាព្រះពុទ្ធ នេះហើយហៅថាសំណាងជាទីបំផុតរបស់ព្រះអង្គ ។

ឯសាមញ្ញសត្វទាំងឡាយក្នុងស្ថានមនុស្សនេះ បើទុកជាស្តេចមហាចក្រពត្រាធិរាជក៏គង់មិនផុតអំពីការកសាងអាយតនៈឡើយ, ព្រះអង្គតែងតែធ្វើការគ្រប់គ្រងនូវអាណាចក្ររបស់ព្រះអង្គ ដោយបុញ្ញារិទ្ធិដែរ ព្រោះសភាពនៃស្ថានមនុស្សជាស្ថានតាំងនៅក្នុងសេចក្តីកសាងទាំងអស់ ។ ការដេកចាំសំណាងមោឃៈ ជាអំពើទំនាស់យ៉ាងធំនាំឲ្យខូចវឌ្ឍនធម៌របស់មនុស្សទាំងមូល ។

ដូច្នេះ ការថែទាំអាយតនៈទាំងពួងឲ្យមានសុខភាពពេញលេញទឹង ការកសាងអាយតនៈទាំងនោះតទៅទៀតដោយកិច្ចទាំងឡាយ គឺការរៀន មើល - ស្តាប់ - ស្រង់ក្លិន និយាយ - ធ្វើ - គិត ដូចបានបរិយាយមក ហើយនេះ ជាការសំខាន់បំផុតសម្រាប់មនុស្សជាតិ ព្រោះអាចញុំាងខ្លួនឲ្យបានកើតទៅជាអ្នកមានសំណាងពេញបរិបូណ៌ ។

តៃ - ជុន

---

## សេចក្តីដកស្រង់ពីច្បាប់សុភាសិត

ឧកញ៉ាព្រះឃ្លាំង ឯង

អសន្តោសោ យតិនដ្ឋោ មហិបតី សន្តុដ្ឋោស លជ្ជាគ-ណី កាននលជ្ជី កុលំឆរា ។ និទានបន្ទ បាលីថាឯ ភិក្ខុឯណា មួយមិនសន្តោស ទោសទុក្ខពុំជា ប្រយោជន៍អត្ថិកា- សារសោះសូន្យសល់ ។ មួយទីក្សត្រា - ធិរាជបេស្តា រ័ក្សព្រស្តមណ្ឌល បើមានសន្តោស ទុក្ខទោសអំពល់ អំពើពុំស្កល់ រាជរម្យរដ្ឋ ។ មួយស្រីផ្កាមាស បើមានចិត្តខ្មាស ពេកពុំបានជា ប្រយោជន៍នៃប្រាណ ពុំបានទ្រព្យា អគ្គីតអ្នកណា ចូលចង់អគ្គប្រាណ ។ មួយនីអ្នកណា មួយមានពង្សា ត្រកូលសន្តាន បើមិនមានខ្មាស ពញាសឈ្មានពាន អ្នកនោះទឹងមាន ប្រយោជន៍ពីអ្វី ។

# បញ្ចតន្ត្រៈ (តមក)

ទេវសម៌:ឃើញដូច្នោះហើយ គិតដោយភ័យថា: "យីអាបបកនេះ លួងអីម្ល៉េះ មិនស្គាល់ស្លាប់ទេឬ? គិតលោតែក្ដាត់ក្ដាក់ខ្លួនទៅនៅចន្លោះពាតែទាំងពីរទឹងថ្ពស់ខ្លួនដល់ក្ដីមរណមិនខាន ។ កាលទេវសម៌:កំពុងតែរិតក្កដូច្នេះ បបកនោះដែលខ្លួនទៅនៅចំចន្លោះក្បាលនៃពាតែទាំងពីរមែន ព្រោះតែលោភហុតឈាម ក៏ត្រូវពាតែទាំងពីរបោលសម្រុកទន្ទ្រិបស្ពៀតស្លាប់ទៅហោង ។ ទេវសម៌:កាលឃើញបបកស្លាប់សមដូចគំនិតខ្លួនគិត ក៏មានក្ដីអាណិតយំសោកស្ដាយដោយប្រការផ្សេងៗ ហើយក៏ដើរត្រឡប់ទៅកាន់កន្លែងដែលទុកថង់ប្រាក់ខ្លួននោះវិញ ដោយសន្សឹមៗ ព្រោះចិត្តជាប់នឹងអារម្មណ៍បបកស្លាប់នោះ លុះដើរទៅដល់មិនឃើញអាសាឍភូតិ នឹកក្ដុកសង្ស័យស្ទុះទៅសើរើពិនិត្យមើលសំពត់ដែលខ្ចប់ថង់ប្រាក់ក្ដាម ដល់រកថង់ប្រាក់មិនឃើញក៏ដឹងច្បាស់ថា: "ឱ! ឱ! អាចោរចិលលួចយកអស់រលីងហើយតើ!" គាត់ក៏ដួលត្លុំសន្លប់បាត់ស្មារតីមួយរំពេច តមក គាត់មានស្មារតីដឹងខ្លួនឡើងវិញ ក្រោកឈរឡើងស្រែកទ្រហោយំថា: 'យីអាសាឍភូតិចង្រៃ! អាចោរចិល! អាឯងមកបោកបញ្ឆោតអញ ឥឡូវអាឯងទៅឯណា? ឆ្លើយប្រាប់អញមក?" ។ បរិព្វាជកទេវសម៌: កើតទុក្ខយំខ្សឹកខ្សួលដោយប្រការផ្សេងៗដើរសន្សឹមៗបណ្ដើរ ពិនិត្យមើលស្នាមជើងចោរបណ្ដើរ ដើរ

តិចៗ ដូច្នេះ ដរាបដល់ពេលសន្ធិយារាត្រី ទើបដល់ទៅភូមិមួយទៅជួបនឹងអ្នកជម្ញាញម្នាក់ បណ្ដើរភរិយាដើរចេញពីភូមិនោះទៅកាន់ក្រុងជិតខាងដើម្បីផឹកស្រាក្នុងពិធីបូជា គាត់ក៏និយាយអង្វរថា : "នែអ្នកដ៏ចំរើន ! អាត្មាចូលមករកអ្នកសូមអ្នកជ្រកអាស្រ័យបានមួយពេលយប់នេះ អាត្មាឥតមានស្គាល់នរណាទេនៅក្នុងភូមិនេះ សូមឲ្យអ្នកមេត្តាបំពេញអតិថិធម៌ទៅចុះ ព្រោះថា :–

១៧០ – ភ្ញៀវណា មកដល់ផ្ទះនៅពេលល្ងាចក្រោយដែលព្រះអាទិត្យអស្តង្គត ម្ចាស់ផ្ទះមិនត្រូវបដិសេធទេ កាលបើបានគោរពបូជាភ្ញៀវនោះដោយប្រពៃហើយ នឹងបានទៅកើតជាទេវតា ។

១៧១ – ស្មៅ (សម្រាប់ដុតបំភ្លឺ) ១ ភូមិ ១ ទឹក ១ ពាក្យពិរោះ ១ ទាំង ៤ នេះ មិនដែលខ្វះកន្លះនៅក្នុងផ្ទះនៃលោកសប្បុរសទាំងឡាយ មិនជាកាលណាទេ ។

១៧២ – ភ្លើងត្រេកអរដោយឧសដែលមកដល់ ព្រះឥន្ទ្រត្រេកអរដោយការក្រាលអាសនៈទុកថ្វាយ គោវិន្ទ: (វិស្ណុ) ត្រេកអរដោយការលាងជើង ព្រះសម្ភុ(១) ត្រេកអរដោយព្រះទេវតាពាក់កណ្ដាលថ្វាស ឯភ្ញៀវក៏ត្រេកអរដោយការទទួលដូច្នោះដែរ ។

---

១ ព្រះឥស្សរ ។

កាលអ្នកតម្បាញបានស្ដាប់ពាក្យទេវសមិៈរូបហើយ កើតសេចក្ដីជ្រះថ្លាបែរទៅនិយាយនឹងភរិយាថា: "នែនាងអើយនាង! នាងឯងចូរនាំភ្ញៀវនេះត្រឡប់ទៅផ្ទះវិញទៅ មើលលាងជើង រៀបភោជនាហារប្រគេន រៀបគ្រែឲ្យអាស្រ័យដំណេកឲ្យស្រួលបួល ហើយទៅថែទាំមើលនៅផ្ទះចុះ អញទៅនឹងយកស្រាយ៉ាងច្រើនមកឲ្យនាងឯង" ៗ អ្នកតម្បាញនិយាយផ្ដែផ្ដាំភរិយារួចហើយក៏ដើរចេញទៅ ៗ ឯភរិយានោះជាស្ត្រីចិត្តបើកបានប្ដីបណ្ដោយដៃដូច្នោះ រីករាយសប្បាយចិត្តណាស់ នាំអ្នកបួសយើងត្រឡប់ទៅផ្ទះវិញ អរផ្អកៗក្នុងពោះ ទឹកមុខឡើងស្រស់បំព្រង ទឹកមមៃទៅគួសង្ស័យឈ្មោះទេវទត្ត, ព្រោះថា:–

១៧៣– ក្នុងពេលមេឃមីស្រទំ ក្នុងពេលងងឹត ក្នុងផ្លូវដែលគេទៅបានដោយលំបាកក្នុងផ្លូវដែលទៅកាន់ក្រុង ស្ត្រីចិត្តបើក ដែលមានប្ដីទៅកាន់ប្រទេសឆ្ងាយហើយ តែងសំដែងសេចក្ដីសប្បាយរីករាយក្រៃលែង ៗ

១៧៤– ស្ត្រីធុត្តកាម លោកក្នុងក្ដីត្រេកអរចំពោះសហាយ សំគាល់ឃើញនូវគ្រឿងកំពលនៅលើគ្រែវិសេស នូវប្ដីថ្មីថ្មរ នូវទីដេកមានតម្លៃច្រើន ថាដូចជាស្មៅ បន្តិចម្ដង ៗ ៗ

១៧៥– សេចក្ដីអៀនខ្មាស ដុតបង់ នូវសេចក្ដីកំសាន្ត, ស្រិង្គារ ដុតបង់ នូវផ្អឹងទាំងឡាយ, សំដីចែចង់គ្នា ដុតបង់ នូវសំដីជូរចត់, សេចក្ដីពេញចិត្តនៃស្ត្រីចិត្តបើក មិនគប្បីមានចំពោះប្ដីដែលមិនស្រឡាញ់គ្នា ៗ

១៧៦ – ស្ត្រីចិត្តចើក ដែលមានចិត្តស្រឡាញ់ប្រុសដទៃហើយ តែងនាំឲ្យត្រកូលធ្លាក់ចុះផង ឲ្យបានពាក្យនិន្ទាពីមនុស្សលោកផង ឲ្យដាច់ចំណងផង ឲ្យអន្តរាយដល់ជីវិតផងមួយរំពេច ។

ឯនាងភរិយានោះ លុះមកដល់ផ្ទះហើយ ក៏រៀបគ្រែកំបាក់កំពុក ឥតពុកឲ្យទេវសម៉ះរួចស្រេចហើយ ទើបនិយាយប្រាប់ថា "នែគក់ន ! ខ្ញុំករុណា មានការទៅជួបនឹងម្នាក់ម្នាក់នៅភូមិខាងនោះ ខ្ញុំករុណាទៅនិយាយការរួចហើយនឹងត្រឡប់មកវិញភ្លាមទេ ក្នុងពេលខ្ញុំករុណាមិននៅទីនេះ សូមកគក់នមើលផ្ទះឲ្យខ្ញុំករុណាផង" ។ នាងចិត្តសាវ៉ លុះនិយាយផ្តែផ្តាំរួចហើយគ្រាប់តែងស្អិតស្អាងខ្លួនប្រាណ ស្រស់ប្រិមប្រិយ ក៏ដើរចេញទៅដំណើរញ៉ែងញ៉ង សំដៅទៅផ្ទះទេវទត្ត ដើរទៅមួយស្របក់ ទៅជួបអ្នកគម្លាញផាប្ដីកំពុងស្រវឹងទោរដែលត្រឡប់មកវិញ ដំណើរទ្រេតទ្រោតៗ ដ្រុលដ្រេក សក់ក្រញេងក្រញាង ទប់ស្មើរតែគ្រប់ជំហានដើង នៅដៃមានស្រាមួយកំប៉ុកផង ។ នាងឃើញប្ដីហើយ វិលត្រឡប់វិញភ្លាម ចូលក្នុងផ្ទះផ្ទុកដោះស្បៀងតែងមួយរំពេច ហើយធ្វើប្ញកដូចប្រក្រតីដើម ដូចឥតដឹងឥតយល់ ។ ឯអ្នកគម្លាញកាលឃើញប្រពន្ធតែងខ្លួនកុំផានល្អចំណាប់វិលទៅផ្ទះវិញ នឹកឃើញរឿងដើម ព្រោះធ្លាប់បានឮពាក្យពេចន៍គេនិយាយពីចរិយាប្រពន្ធខ្លួន តែលាក់បិទបាំងគំនិតសង្ស័យនោះមិនហ៊ានឲ្យលេចឮ អាម៉ាស់គ្រួខ្លួន

ដល់មកឃើញពិតច្បាស់នឹងភ្នែកប្រច័ក្ស កើតខ្ញាញ់មួម៉ៅក្តៅក្រហាយ ឆេះដូចភ្លើង ចូលទៅដល់គន់ផ្ទះក៏ស្រែកសួរទៅប្រពន្ធថា "នែមេសំផឹងចង្រៃ ! មេហិនឯងទៅណាអំបាញ់មិញនេះ?" ។ ភរិយាឆ្លើយតបភ្លាមថា: "តាំងពីអញឃ្លាតពីឯងមក អញមានទៅឯណាអញ ហេតុអ្វីក៏អាប្រមឹកស្រវឹងខ្លួនឯងចូលមកដល់ដូចឆ្កួត ស្រាប់តែរករឿងឈ្លោះដូច្នេះ? ព្រោះថា :—

១៧៧ — សេចក្តីស្រវឹង នាំបណ្តាលឲ្យស្គាល់លក្ខណៈរោគទាំងអស់ មានប្រជុំមេរោគគឺ វិកលចរិត ការដួលដេកលើផែនដី ការនិយាយរអ៊ូជានិច្ចជាដើម ។

១៧៨ — ការញ័រដៃ ការអាក្រាតសំពត់នឹងការឡើងសម្បុរក្រហមជាសភាពតែងកើតពីការញៀនទឹកស្រវឹង ដូចជាព្រះអាទិត្យដែលបាត់រស្មី អស់ពន្លឺឡើងពណ៌ក្រហមដូច្នោះឯង ។

អ្នកតម្បាញបានស្តាប់ពាក្យតំរេះតំរើយភរិយាហើយ ព្រមទាំងឃើញផ្លាស់គ្រឿងតែងខ្លួនផង ស្រែកសន្ធាប់ទៅវិញថា: "យើមេសំផឹង ! អញបានឮរឿងរ៉ាវពីបុកមេសំផឹងឯងមកយូរយារណាស់ហើយ តែអញលាក់បិទបាំង ថ្ងៃនេះ អញបានឃើញសេចក្តីពិតផ្ទាល់ខ្លួនទៀត អញនឹងដាក់ទណ្ឌកម្មមេហិនឯងឲ្យដល់ខ្នាតឥឡូវនេះ" និយាយរួចហើយគាត់កាន់ព្រនង់មកសំពងភរិយាច្រើនព្រនង់ទាល់តែទ្រម ហើយយកខ្សែមកចង

ផ្អោបនឹងសសរមួយទុកចោលនៅទីនោះទៅ ឯខ្លួនគាត់ដោយស្រវឹងជ្រុលពេក ចូលទៅកាន់ដំណេកប្រះខ្លួនដេកលក់ទៅដែរ ។ ក្នុងពេលនោះឯង ភរិយាអ្នកកាត់សក់ កាលដឹងថាអ្នកជម្បាញដេកលក់ហើយ ក៏ចូលមករកម្រាក់ខ្លួនហើយនិយាយថា "នែម្រាក់អើយ! ទេវទត្តនៅចាំម្រាក់ឯងឯណោះ, ទៅ! ទៅឲ្យឆាប់ទៅ ។ ប្រពន្ធអ្នកតម្បាញឆ្លើយទៅវិញថា ចុះម៉េចក៏ម្រាក់ឯងមិនមើលគ្នា! ម្រាក់ត្រឡប់ទៅវិញទៅ ទៅប្រាប់សហាយខ្ញុំផង ថាខ្ញុំជាប់ចំណងទៅហើយ ទៅជួបមិនបានទេពេលនេះ" ។ ភរិយាអ្នកកាត់សក់និយាយថែមទៀតថា "ទេម្រាក់! ម្រាក់ឯងកុំនិយាយដូច្នេះ និយាយនេះដូចជាម្រាក់ឯងទាល់គំនិត មិនមែនជាស្ត្រីបេះដូងវិលខូច, ព្រោះថា :–

១៧៩ – ជនណាតាំងចិត្តដាច់ខាតនឹងតាំងចិត្តម៉ឺងម៉ាត់ថានឹងទៅយកផ្លែឈើដែលមានទុជារសឆ្ងាញ់ពីសានៅក្នុងឋានទុគេម ខ្ញុំជឿជាក់ថាជីវិតនៃជននោះដូចសត្វទន្ទ ជាជីវិតគឺបុគ្គលគប្បីបូជា ។

១៨០ – បរលោកមិនទៀងទាត់ក្នុងលោកនេះ ពាក្យនិន្ទាមានច្រើនប្រការណាស់ ហេតុនោះ ស្រីដែលនៅទទួលតារុណ្យផល(១) គឺនៅវ័យក្មេង បានទៅសហាយនឹងប្រុសដទៃហើយធ្វើឲ្យនៅក្នុងអំណាចខ្លួន ទុកជាស្រីមានសំណាងធំណាស់ ។

---

១ ផលគឺភាពនៃខ្លួននៅក្មេង ។

១៨១ – ថាបើស្រីវិលខ្ចប់ទៅបានប្រុសសហាយរូបអាក្រក់តាម តែសំណាងខ្លួនក្នុងទីស្ងាត់ តែងលះបង់ប្ដីខ្លួនឯងដែលមានរូបល្អជាទីស្រឡាញ់ពេញចិត្តដែលរកបានដោយក្រ ហោលពុំខាន ។

ប្រពន្ធអ្នកតម្បាញពោលឡើងថា "នែម្នាក់! បើដូច្នោះមានតែម្នាក់សុខចិត្តឲ្យខ្ញុំចងជំនួសខ្ញុំ ទើបខ្ញុំចេញទៅបាន មួយទៀត ប្ដីខ្ញុំចិត្តអាក្រក់ណាស់ នៅក្នុងទីជិតនេះផង ។ ប្រពន្ធអ្នកកាត់សក់ឆ្លើយគាត់ថា: "ម្នាក់អើយ! មិនថ្វីទេ គាត់កំពុងស្រវឹងឈ្ងុបមុខ មិនងាយដឹងខ្លួនក្រោកឡើងទេ វៀងតែដល់ព្រះអាទិត្យរះឡើងទើបក្រោកបាន, បើដូច្នោះ ខ្ញុំស្រាយម្នាក់ឯង ហើយម្នាក់ឯងចងខ្ញុំជំនួសវិញ ទៅជួបមុខទេវទត្តឲ្យបានសប្បាយរួចចិត្តហើយចូរត្រឡប់មកវិញឲ្យឆាប់ ៗ" ។ ប្រពន្ធអ្នកជម្បាញឆ្លើយតបថា: "អើម្នាក់! ហើយដើរចេញទៅ ។ ក្រោយកាលដែលស្រីពីរនាក់និយាយគ្នារួចហើយ អ្នកតម្បាញស្វាងស្រាបន្តិចក៏ក្រោកឡើងហើយស្រែកសួរទៅប្រពន្ធថា: "នែមេកាឡកណ្ណី! មេចោរដកទង! ពីថ្ងៃនេះទៅ ថាបើមេហ៊ានឯងលែងចេញពីផ្ទះ ទឹងលែងនិយាយជាមួយប្រុសទៀត នោះអញនឹងស្រាយលែងមេហ៊ានឯងឥឡូវ ។

(មានត)

IMPRIMERIE ROYALE